# ការកើតពុំគ្រប់លក្ខណៈ

**(Birth Defects)**
**WUML**
**1/7/07**

នៅសប្តាហ៍នេះ ខ្ញុំបាទមានកិត្តិយសនឹងសូមជំរាបជូនអស់លោក-លោកស្រី អំពីការដែលទារកកើតពុំគ្រប់លក្ខណៈ ដោយអធិប្បាយអំពីមូលហេតុ, បញ្ហាទាក់ទងទៅនឹងការទទួលទានសុរាឬបារី, ការចាត់ចែងវិធីព្យាបាល, និងផលប្រយោជន៍នៃការថែរក្សាគភ៌។

មកទល់នឹងពេលបច្ចុប្បន្ននេះ គេពុំទាន់ដឹងច្បាស់អំពីមូលហេតុនៃការកើតពុំគ្រប់លក្ខណៈ នៅឡើយទេ។ ជួនកាលទារកស្រាប់តែកើតមកយ៉ាងដូច្នេះឯងតែម្តង គឺពុំមែនបានន័យថា មកពីកំហុសរបស់ឪពុកម្តាយនោះឡើយ។ ឪពុកម្តាយជាច្រើន បានដាក់កំហុសទៅលើខ្លួនឯង ថាមកពីខ្លួនបានជាកូនកើតមកយ៉ាងដូច្នេះ។ ប្រសិនបើ លោកអ្នកមានកូនកើតពុំគ្រប់លក្ខណៈ ជាការមួយសំខាន់ គួរជជែក ឬពិគ្រោះជាមួយឪពុកម្តាយដទៃទៀត ដែលមានបញ្ហាដូចគ្នាដែរ។ ជួនកាល យើងអាចពិចារណាអំពីមូលហេតុខ្លះៗ បានបន្ទាប់ពីទារកកើតហើយ។ ជាការមួយសំខាន់គួរដឹងអំពីវិធីខ្លះៗ ដែលអ្នកគួរអនុវត្ត ដើម្បីឲ្យទារកមានសុខភាពបរិបូរណ៍ទៅអនាគត។

ការកើតពុំគ្រប់លក្ខណខ្លះ អាចមានការទាក់ទងទៅនឹងម្តាយដែលទទួលទានបារី នៅពេលមានផ្ទៃពោះ។ ស្ត្រីដែលទទួលទានបារីនៅពេលមានផ្ទៃពោះ អាចបណ្តាលឲ្យទារកកើតពុំគ្រប់ខែ, កើតមកតូច, ឬស្លាប់ក្នុងពោះ។ ជួនកាល អាចធ្វើឲ្យកូនស្លាប់ក្នុងចន្លោះបានអាយុមួយឆ្នាំ។ បញ្ហាដទៃទៀតមានដូចជា៖ កូនកើតមកកញ្ជួតបបូមាត់ឬច្រមុះ, កញ្ជ្រត់កណ្តើត, ជើងកែក, ខូចដៃជើង, កើតរោគបេះដូង, សរសៃពោះស្តើងធ្វើឲ្យ ពោះវៀនចេញមកក្រៅ និងគ្មានរន្ធគូថសំរាប់បន្ទោរលាមក។ ដើម្បីជៀសវាងលក្ខណៈទាំងនេះ អ្នកគួរពិភាក្សាជាមួយគ្រូពេទ្យ ដើម្បីរកមធ្យោបាយឈប់ទទួលទានបារី នៅពេលមានផ្ទៃពោះ ឬនៅពេលមានគំរោងការណ៍ចង់បានកូន។

ឯការកើតពុំគ្រប់លក្ខណខ្លះទៀត អាចមានការទាក់ទងទៅនឹងម្តាយដែលទទួលទានសុរា នៅពេលមានផ្ទៃពោះ។ លក្ខណៈរោគដែលបណ្តាលមកពីម្តាយទទួលទានសុរានៅពេលមានផ្ទៃពោះភាសាអង់គ្លេស ហៅថា **Fetal Alcohol Syndrom** អាចបណ្តាលឲ្យទារកកើតមកមានបញ្ហាខួរក្បាល, កើតពុំគ្រប់លក្ខណៈ និងមានបញ្ហាសុខភាពទាំងផ្នែករាងកាយនិងផ្នែកផ្លូវចិត្ត អស់មួយជីវិត។ បញ្ហានេះ ធ្វើឲ្យទារកកើតមក មានទំរង់មុខខុសប្រក្រតិ, ពុំធំធាត់ដូចក្មេងដទៃ, និងមានបញ្ហាសរសៃប្រសាទ។ ក្មេងទាំងនេះ ច្រើនរៀនសូត្រ ពុំសូវចេះចាំ, ពុំមានលទ្ធភាពអាច

ដោះស្រាយបញ្ហាផ្សេងៗបាន, និយាយពុំច្បាស់, និងថ្លង់ ហើយដែលជាហេតុ បណ្តាលឲ្យក្មេងមានការពិបាកក្នុងការសិក្សា ហើយច្រើនមានរឿងរ៉ាវជាមួយក្មេងដទៃទៀតផង។ លក្ខណៈនេះពុំអាចកែបាននិញទ្បើយ គឺបានន័យថា ក្មេងត្រូវរស់នៅ ដោយមានលក្ខណៈប្រភេទនេះអស់មួយជីវិត។ ប៉ុន្តែ រោគដែលបណ្តាលមកពីម្តាយទទួលទានសុរានៅពេលមានផ្ទៃពោះ ហៅថា **Fetal Alcohol Syndrome** វិញ អាចការពារបាន 100% ប្រសិនបើ ម្តាយអាចជៀសវាងកុំទទួលទានសុរានៅពេលមានផ្ទៃពោះបាន។

នៅក្នុងសហរដ្ឋមានទារកចំនួន 3% ដែលកើតមកដោយពុំគ្រប់លក្ខណៈ។ ស្ត្រីខ្លះអាចមានទារកកើតមកពុំគ្រប់លក្ខណៈជាងស្ត្រីឯទៀត។ ស្ត្រីដែលមានផ្ទៃពោះក្នុងពេលមានអាយុពី 35 ឆ្នាំឡើងទៅ អាចមានបញ្ហានេះ ច្រើនជាងស្ត្រីដែលក្មេងជាងអាយុ 35 ឆ្នាំ។ ទារកច្រើនកើតមកមានលក្ខណៈ ដែលភាសារអង់គ្លេសហៅថា Down Syndrome ។ ស្ត្រីខ្លះអាចមានទារកកើតពុំគ្រប់លក្ខណៈ ប្រសិនបើគាត់ទទួលទានថ្នាំអ្វីម៉្យាងនៅពេលមានផ្ទៃពោះ។ ជួនកាលម្តាយដែលទទួលទានបារី ឬសុរានៅពេលមានផ្ទៃពោះក៏បណ្តាលឲ្យទារកមានបញ្ហាយ៉ាងដូច្នោះដែរ។ ម៉្យាងទៀត គឺដោយសារម្តាយមានបងប្អូនដែលធ្លាប់មានទារកកើតពុំគ្រប់លក្ខណៈ។ ដើម្បីចង់ដឹងអំពីជម្ងឺតពូជ អ្នកគួរពិភាក្សាជាមួយគ្រូពេទ្យឯកទេសខាងជម្ងឺតពូជ ហើយសូមសាកសួរគ្រូពេទ្យ ប្រសិនបើអ្នកទទួលទានថ្នាំអ្វីមួយ។ ជាពិសេស ជៀសវាងដាច់ខាត កុំទទួលទានសុរា ឬបារី ហើយទទួលទានថ្នាំ ជាតិវិតាមិន B និង Folic acid ឲ្យបានរាល់ថ្ងៃ។

ប្រសិនបើ លោកអ្នកមានទារកដែលកើតមកពុំគ្រប់លក្ខណៈ គ្រូពេទ្យប្រចាំគ្រួសារ ជាអ្នកព្យាបាលជម្ងឺទូទៅ របស់ទារកលោកអ្នក។ គ្រូពេទ្យនោះ អាចដឹងអំពីប្រភពជំនួយផ្សេងៗដែលអាចជួយឧបត្ថម្ភដល់គ្រួសារលោកអ្នកបាន។ ជំនួយទាំងនេះ គឺមានដូចជា៖ ជំនួយសុខភាពសាធារណៈ និងពត៌មានអំពីឱសថផ្សេងៗ ជាដើម។ គ្រូពេទ្យនោះ នឹងចាត់ចែងវិធីព្យាបាលទាំងឡាយដែលក្មេងត្រូវការចាំបាច់។ ឧទាហរណ៍ ប្រសិនបើកូន កើតពុំគ្រប់លក្ខណៈទាក់ទងនឹងបញ្ហាឆ្អឹង គាត់នឹងបញ្ជូនទៅគ្រូពេទ្យឯកទេសខាងឆ្អឹង; ប្រសិនបើកូន មាន បញ្ហាទាក់ទងទៅនឹងខួរក្បាល និងសសៃប្រសាទ គាត់នឹងបញ្ជូនទៅគ្រូពេទ្យឯកទេសខាងសសៃប្រសាទ។ ជួនកាលគ្រូពេទ្យប្រចាំគ្រួសារ អាចបញ្ជូនកូនលោកអ្នកទៅកម្មវិធីជួយឲ្យធ្វើសកម្មភាពបានគ្រាន់បើ។ កម្មវិធីដែលគ្រូពេទ្យច្រើនបញ្ជូនទៅគឺ គ្រូពេទ្យហាត់ធ្វើចលនា Physical Therapy ដើម្បីឲ្យក្មេងមានកម្លាំងមាំមួននឹងធ្វើចលនាបានរឹងមាំ។

ទារកដែលកើតពុំគ្រប់លក្ខណៈ ច្រើនមានបញ្ហាសុខភាពចំរុះ ហើយត្រូវការគ្រូពេទ្យឯកទេសច្រើននាក់។ ដូច្នេះហើយ បានជាគ្រូពេទ្យប្រចាំគ្រួសារត្រូវការបញ្ជូនកូនលោកអ្នក ដើម្បីទៅ

ទទួលជំនួយដែលគ្នាត្រូវការ។

ដោយសង្ខេប ទារកដែលកើតមកពុំគ្រប់លក្ខណៈ មានច្រើន ប៉ុន្តែក្នុងពេលបច្ចុប្បន្ននេះ គេនៅតែពុំទាន់ដឹង អំពីមូលហេតុឲ្យបានច្បាស់លាស់ នៅឡើយទេ។ គ្រូពេទ្យប្រចាំគ្រួសារ ជាគ្រូពេទ្យយ៉ាងចំណានម្នាក់ ក្នុងការចាត់ចែងវិធីព្យាបាលកូនរបស់លោកអ្នក។

ដើម្បីរក្សាទារកក្នុងផ្ទៃឲ្យមានសុខភាពល្អ អ្នកគួរ៖

- អញ្ជើញទៅពិនិត្យសុខភាពមុនពេលមានផ្ទៃពោះ,
- រៀបចំព្យាបាលជម្ងឺឬបញ្ហាសុខភាពផ្សេងៗសិន មុននឹងចាប់ផ្តើមមានផ្ទៃពោះ។ ជម្ងឺទាំងនេះមាន ដូចជា ការធាត់ហួស, ជម្ងឺទឹកនោមផ្អែម, ជម្ងឺស្កន់ ឬប្រកាច់ជាដើម។
- ទទួលទានថ្នាំវីតាមីន Folic acide នៅពេលមុនមានផ្ទៃពោះ និងពេលកំពុងមានផ្ទៃពោះ។
- ព្យាយាមថែរក្សាសុខភាពខ្លួនអ្នកដោយ
    - សំរាកឲ្យបានគ្រប់គ្រាន់,
    - ធ្វើការហាត់ប្រាណឲ្យបានល្មម,
    - ទទួលទានចំណីអាហារឲ្យបានត្រឹមត្រូវទៅតាមកំណត់,
    - ជៀសវាងប៉ះពាល់ជាមួយជាតិគីមីផ្សេងៗ ដែលអាចផ្តល់វិបត្តិដល់ទារកក្នុងពោះ,
    - ជៀសវាងទទួលទានសុរា, បារី, និងគ្រឿងញៀនផ្សេងៗ និង
    - ពិភាក្សាជាមួយគ្រូពេទ្យមុនពេលប្រើថ្នាំអ្វីផ្សេងៗ

ការមួយសំខាន់បំផុត ប្រសិនបើអ្នកចង់មានផ្ទៃពោះ ឬកំពុងមានផ្ទៃពោះ គឺអញ្ជើញទៅជួបជាមួយគ្រូពេទ្យរបស់អ្នក។ ការអញ្ជើញទៅពិនិត្យផ្ទៃពោះ អាចជួយឲ្យគ្រូពេទ្យរហ័សដឹង អំពីលក្ខណៈខុសធម្មតានៃទារកក្នុងពោះ ហើយចាប់ផ្តើមពិនិត្យតាមដាននិងព្យាបាលមុនពេលឆ្លងទន្លេ។ បញ្ហាខ្លះអាចជៀសវាងបានដោយ អញ្ជើញទៅពិនិត្យផ្ទៃពោះឲ្យបានទៀងទាត់។

ការកើតពុំគ្រប់លក្ខណៈខ្លះ ពុំអាចការពាជាមុនបានឡើយ ប៉ុន្តែស្ត្រីយើង អាចចាត់វិធានការណ៍រក្សាគក៏ឲ្យទារកមានសុខភាពល្អបាន។ ការកើតពុំគ្រប់លក្ខណៈ ច្រើនកើតឡើងនៅពេលស្ត្រីចាប់ផ្តើមមានផ្ទៃពោះជាដំបូង។ ជួនកាលនៅពេលដែលស្ត្រីពុំទាំងដឹងថា ខ្លួនមានផ្ទៃពោះនៅឡើយផង។ សូមមេត្តា ចាំជាក់ថា ការមានផ្ទៃពោះ ក្នុងសហរដ្ឋចំនួនពាក់កណ្តាល គឺកើតឡើង ដោយពុំបានស្មាន ឬគ្រោងទុកជាមុនឡើយ។

ចំពោះពត៌មានបន្ថែម សូមមេត្តាសាកសួរគ្រូពេទ្យប្រចាំកាយរបស់អស់លោក-លោកស្រី ឬទូរស័ព្ទទៅមន្ទីរពេទ្យពិនិត្យផ្ទៃពោះនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលលេខ (978) 446-0788 ដើម្បីធ្វើការណាត់ជួប ឬក៏អានវិបសៃរបស់គ្រិស្ថានជាតិផ្នែកខាងសុខភាពកុមារនិងការលូតលាស់នៃមនុស្សជាតិដែលហៅថា National Institute of Child Health & Human Development ហើយដែលមានអាសយដ្ឋាន [www.nichd.nih.gov](http://www.nichd.nih.gov) ។